# សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង អង្គការយូណេស្កូ

## សេចក្តីជូនដំណឹង

ស្តីពីការប្រកួតស្នាដៃសិល្បៈដើម្បីចូលរួមលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបីទាំងប្រាំរបស់កម្ពុជា ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បអរូបីរបស់អង្គការយូណេស្កូ មានដូចជា៖ របាំព្រះរាជទ្រព្យ ឆ្នាំ២០០៣, ល្ខោនស្រមោលលស្បែកធំ ឆ្នាំ២០០៥, ល្បែងទាញព្រ័ត្រ ឆ្នាំ២០១៥, ចាប៉ីដងវែង ឆ្នាំ២០១៦ និងល្ខោនខោលវត្តស្វាយអណ្តែត ឆ្នាំ២០១៨។

**គោលបំណងនៃការប្រកួតប្រជែង៖**

ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌អរូបីរបស់កម្ពុជាជារួម និងដោយឡែកអំពីបេតិកភណ្ឌវប្បធម៌អរូបី ដែលបានចុះបញ្ជីរួចហើយ និងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋកម្ពុជាបង្ហាញទេពកោសល្យ និងបកស្រាយអំពីបេតិកភណ្ឌវប្បធម៌អរូបីកម្ពុជា។ ក្រោយពេលវាយតម្លៃរួច ស្នាដៃទាំងអស់នឹងត្រូវបង្ហោះនៅបណ្តាញសង្គមរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង អង្គការយូណេស្កូភ្នំពេញ។

**ស្នាដៃចូលរួមប្រកួតមាន៖**

១. គំនូរវិចិត្រកម្ម (ជា Hard copy: A2 ឬ ជា Soft Copy: 5MB) សម្ភារៈសេរី (សខ្មៅ ព័ណ៌ទឹក ពណ៌ប្រេង PASTEL …)

២. ថតរូប (ផ្តិតរូបលើក្រដាសទំហំ A3 ឬជា Soft Copy: 3MB)

៣. រចនាក្រាហ្វិច(លើក្រដាសទំហំ A3 ឬជា Soft Copy: 3MB)

**ជ័យលាភី៖**

- លេខ១៖ រង្វាន់១លានរៀល ប័ណ្ណសរសើរមួយ និងរង្វាន់លើកទឹកចិត្តផ្សេងៗទៀត
- លេខ២៖ រង្វាន់៥សែនរៀល ប័ណ្ណសរសើរមួយ និងរង្វាន់លើកទឹកចិត្តផ្សេងៗទៀត
- លេខ៣៖ រង្វាន់៤សែនរៀល ប័ណ្ណសរសើរមួយ និងរង្វាន់លើកទឹកចិត្តផ្សេងៗទៀត

**កាលបរិច្ឆេទ៖**

- ចុះឈ្មោះចូលរួមប្រកួតប្រជែងតាមរយៈលោក **ឈូក រិទ្ធី** មន្ត្រីកម្មវិធីសិក្សានៃមហាវិទ្យាល័យសិល្បៈសូនរូប ចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ តទៅ។
- ស្នាដៃត្រូវប្រគល់ជា hard ឬ soft copy មកមហាវិទ្យាល័យត្រឹមថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។
- ប្រកាសជ័យលាភីនៅថ្ងៃទី១៥ ខែមិនា ឆ្នាំ២០២២។

**ទូរស័ព្ទទាក់ទង៖** ០១៧ ២០០ ៤៦២/០១១ ៩០៦ ២៥៩

Telegram៖ ០៨៩៥៥៦៦៩៨

<u>បញ្ជាក់</u>៖ កម្មវិធីនេះ គឺសម្រាប់តែសិស្ស និងនិស្សិតមកពីស្ថាប័នអប់រំនានានៃព្រះរាជាណាចក្រកម្ពុជា។